00203860

C22/I/59

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / July / 2008
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**កាលបរិច្ឆេទ:** ១៤ កក្កដា ២០០៨

---

# សេចក្តីណែនាំបន្ថែមទាក់ទងនឹងពាក្យសុំឲ្យពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRELIMINAIRE

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

១- **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ក.ត" បានឃើញ "ពាក្យសុំឱ្យពិចារណាឡើងវិញ អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ" ("ពាក្យសុំ") ដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី **សេខ ឆារី** ("ដើមបណ្តឹងរដ្ឋប្បវេណី") នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ និង "សេចក្តីណែនាំដល់ភាគីអំពីពាក្យសុំឱ្យពិចារណាឡើងវិញអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ" ដែលបានដាក់ដោយអង្គបុរេ-ជំនុំជម្រះ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៨។

២- នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះទទួលបានសំបុត្រមួយច្បាប់ពីអ្នកស្រី Sarah Thomas នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៨ ដែលលិខិតនោះបាននិយាយពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់បានឡើងថ្លែង ក្នុងសំណុំរឿងលេខ ០០១ របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើពាក្យសុំនេះ។

៣- ដោយទទួលស្គាល់ពីផលប៉ះពាល់ជាសក្តានុពល ចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើពាក្យសុំអំពីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់បានឡើងថ្លែង អង្គបុរេជំនុំជម្រះយល់ឃើញថា វាគួរទទួលបានផលប្រយោជន៍នៃយុត្តិធម៌ក្នុងកាលៈទេសៈទាំងនេះ ដើម្បីផ្តល់ឱកាសឱ្យធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងពាក្យសុំនេះ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះណែនាំថា:**

*សេចក្តីសន្និដ្ឋានតបណាមួយពីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០១ របស់សហចៅក្រមស៊ើបអង្កេត និងពីសហមេធាវីការពារក្តីរបស់ជនត្រូវចោទដទៃទៀត ត្រូវដាក់ត្រឹមម៉ោង **៤ រសៀល នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៨** ជាកំហិត។*

*សេចក្តីសន្និដ្ឋានទាំងអស់ ត្រូវគោរពតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក អ.វ.ត.ក/០១/២០០៧/កែប្រែលើកទី២។*

ភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**

00203862

C22/I/59

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ**
**ខណ្ឌដង្កោ ក្រុងភ្នំពេញ**

**សូមគោរពលោកនិងលោកស្រីចៅក្រមនៃអង្គបុរេជំនុំជម្រះ**

នាងឈ្មោះ **សារ៉ា ថូម៉ាស** ជាសមាជិកផ្នែកច្បាប់នៅក្នុងគម្រោងចូលរួមរបស់ជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។ ដូចលោកនិងលោកស្រីចៅក្រមជ្រាបស្រាប់ហើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានដំណើរការគម្រោងមួយនេះតាំងពីខែតុលា ឆ្នាំ២០០៧ ដើម្បីជួយជ្រោមជ្រែងដល់បុគ្គលដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឱ្យបុគ្គលទាំងអស់នោះអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងនីតិវិធីរបស់តុលាការ។ មកទល់ពេលនេះ គម្រោងរបស់យើងខ្ញុំបានដាក់បែបបទព័ត៌មានស្តីពីជនរងគ្រោះជាង១០០០បែបបទជូនអង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក។

នាងខ្ញុំសសេរលិខិតនេះដែលពាក់ព័ន្ធនឹងសេចក្តីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលបានសម្រេចនៅថ្ងៃទី១ និងថ្ងៃទី២ ខែកក្កដា អំពីការចូលរួមដោយផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការមុនអង្គសេចក្តី។ តាមអ្វីដែលនាងខ្ញុំយល់ សេចក្តីសម្រេចនេះគឺបានធ្វើឡើងដើម្បីរាំងដើមបណ្តឹងរដ្ឋប្បវេណី មិនថាមានឬគ្មានតំណាងមេធាវី ពីការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងសវនាការមុនអង្គសេចក្តី។ អ្វីដែលគួរឱ្យព្រួយបារម្ភបំផុតនោះ សេចក្តីសម្រេចនៅថ្ងៃទី២ បង្ហាញច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានតំណាងមេធាវីគឺមិនមានសិទ្ធិក្នុងការថ្លែងប្រាស័យនៅក្នុងកិច្ចដំណើរការនីតិវិធី។

ថ្ងៃនេះ លោកស្រី គៀត បូផល ប្រធានអង្គភាពជនរងគ្រោះ បានបញ្ជាក់ថា បុគ្គលដែលបានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីរូបដែលគម្រោងយើងខ្ញុំបានជួយជ្រោមជ្រែង កំពុងត្រូវបានគេរៀបចំដាក់បញ្ចូលក្នុងសំណុំរឿងលេខ ១ (តាមខ្ញុំដឹង ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានចូលរួមក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ)។ ដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលដែលបានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ នៅមិនទាន់មានអ្នកតំណាងនៅឡើយ ដោយសារយើងខ្ញុំបន្តស្វែងរកមេធាវីតំណាងដែលមានគុណសម្បត្តិសមរម្យសម្រាប់ពួកគេ។

00203863

C22/I/59

ដោយសារបុគ្គលទាំងអស់នេះមិនទាន់មានមេធាវីតំណាង សេចក្ដីសម្រេចរបស់លោកនិងលោកស្រីចៅក្រមកាលពីថ្ងៃទី១ និងថ្ងៃទី២ នឹងរារាំងការចូលរួមរបស់ពួកគេនៅក្នុងសវនាការមុនអង្គសេចក្ដីនានាដែលអាចបើកការជំនុំជម្រះលើជនត្រូវចោទនាពេលខាងមុខ។ នាងខ្ញុំយល់ឃើញថា វាជាការព្រួយបារម្ភជាខ្លាំងដែលសិទ្ធិរបស់បុគ្គលទាំងនេះត្រូវបានដាក់កម្រិត មុនពេលពួកគេអាចទទួលបានឱកាសធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឬដោយផ្ទាល់មាត់ នៅក្នុងរឿងក្ដីនេះ។

នាងខ្ញុំកត់សម្គាល់ឃើញថា កាលពីថ្ងៃទី២ ខែកក្កដា ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងបានស្នើសុំធ្វើសេចក្ដីសន្និដ្ឋាន ត្រូវបានបដិសេធចោល បានបង្ហាញថា គាត់បានដាក់“សំណើស្នើសុំការពិចារណាសារជាថ្មី” ចំពោះសេចក្ដីសម្រេចមុន។ ក្នុងពេលសវនាការ លោកស្រីចៅក្រម Lahuis បានបញ្ជាក់ថា អង្គបុរេជំនុំជម្រះនឹងធ្វើការពិចារណាសំណើនេះនៅក្នុងពេលសមស្របណាមួយ។ **ដោយសារសេចក្ដីសម្រេចនេះនឹងប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនិងបុគ្គលដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានជួយជ្រោមជ្រែងដោយគម្រោងរបស់យើងខ្ញុំ នាងខ្ញុំចង់ដឹងថាតើបុគ្គលទាំងនេះ (ក្នុងនាមខ្លួនឯងឬក្នុងនាមក្រុមរបស់ខ្លួន) អាចមានលទ្ធភាពធ្វើសេចក្ដីសន្និដ្ឋានសង្ខេប ឬសេចក្ដីសន្និដ្ឋានទាំងឡាយដែលមានទឡ្ហីករណ៍លើកឡើងនៅក្នុងរឿងក្ដីនេះ ដែរឬទេ។** ប្រសិនបើអាចមែននោះ សូមអង្គបុរេជំនុំជម្រះបញ្ជាក់វិធានសមស្រប ដែលយើងខ្ញុំអាចអនុវត្តតាមចំពោះការដាក់សេចក្ដីសន្និដ្ឋាន និងការកំណត់ទំព័រចំពោះចំនុចដែលជាប់ទាក់ទងនឹងរឿងក្ដី។

សូមថ្លែងអំណរគុណចំពោះលោកចៅក្រម ហើយនាងខ្ញុំរង់ចាំទទួលការឆ្លើយតបពីលោកនិងលោកស្រីចៅក្រម។

ដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ

សារ៉ា ថូម៉ាស

សមាជិកផ្នែកច្បាប់

គម្រោងចូលរួមរបស់ជនរងគ្រោះ

មជ្ឈមណ្ឌលឯកសារកម្ពុជា

sjt2110@caa.columbia.edu